**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**ក្រសួងអប់រំ យុវជន និងកីឡា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ៧៥ អយក.គល.ទន

**សេចក្តីជូនដំណឹង**
**ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ**
**ការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេស និងសង្ហារឹមសម្រាប់សាលារៀន**
**ថវិកាកម្មវិធីឆ្នាំ២០១៧ ផ្នែកអប់រំ ជំពូក៦០**
**របស់អង្គភាពថវិកានាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ**

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេស និងសង្ហារឹមសម្រាប់សាលារៀន ថវិកាកម្មវិធីឆ្នាំ២០១៧ ផ្នែកអប់រំ ជំពូក៦០ របស់អង្គភាពថវិកានាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្របតាមបទបញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានអគាររដ្ឋបាលថ្មី(សាលាបឋមសិក្សាចៅពញាហុក)ជាន់ទីពីរ ផ្លូវលេខ៣៨០ សង្កាត់ បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទៈ ០២៣ ២១០ ៤៦៤ /០២៣ ២២០ ៩២៧ ទូរស័ព្ទ/ទូរសារលេខៈ០២៣ ២១៥ ២០២ អ៊ីមែល: procurement@moeys.gov.kh គេហទំព័រ www.moeys.gov. kh/procurement ចាប់ពីថ្ងៃ ២៣ ខែមិថុនា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវកក់ប្រាក់ធានាការដេញថ្លៃ ដែលមានទឹកប្រាក់ចំនួន **២៧ ៤៩២ ០០០រៀល(ម្ភៃប្រាំពីរលាន បួនរយកៅសិបពីរពាន់រៀលគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូរណាមួយដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង ១៤:៣០ សៀលថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើនៅវេលាម៉ោង ១៤:៣០ សៀលថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ